**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥.១៣-០១៧-៩៤.៧.សន.ក

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៤ ឆ្នាំ២០១៧

## ស្តីពី "តួនាទីរបស់បច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា"

ធនាគារជាតិនៃកម្ពុជា មានក្តីសោមនស្សរីករាយ សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានអនុញ្ញាតឱ្យស្រាវជ្រាវលើប្រធានបទ **"តួនាទីរបស់បច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ"** ធនាគារជាតិនៃកម្ពុជាបានទទួលនូវលទ្ធផលនៃការស្រាវជ្រាវ និងគ្រោងរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ លើកទី៤ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៧ ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់ នៅសណ្ឋាគារ សូហ្វីតែល ភូគីត្រា ភ្នំពេញ។

សន្និសីទនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងរួមចំណែកអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅកម្ពុជាលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ និងលើកកម្ពស់ការពិភាក្សារវាងភាគីពាក់ព័ន្ធក្នុងចំណោមអ្នកស្រាវជ្រាវ អ្នកជំនាញ និងអ្នករៀបចំគោលនយោបាយដើម្បីផ្តល់ជាធាតុចូលសម្រាប់ធនាគារជាតិនៃកម្ពុជា ក្រសួង-ស្ថាប័ន ក៏ដូចជាភាគីពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយនិងគាំទ្រការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យហិរញ្ញវត្ថុ។ ជាលទ្ធផល កម្ពុជានឹងអាចបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុបន្ថែមទៀត ដោយប្រសិទ្ធភាព ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងគាំទ្រកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព សមភាព និងបរិយាប័ន្ន ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល។

ចំពោះការចូលរួមក្នុងសន្និសីទខាងលើនេះ ធនាគារជាតិនៃកម្ពុជានឹងផ្ញើលិខិតអញ្ជើញទៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏នឹងទុកលទ្ធភាពមួយចំនួនសម្រាប់អ្នកស្រាវជ្រាវ អ្នកជំនាញ និងអ្នករៀបចំគោលនយោបាយដែលមានចំណាប់អារម្មណ៍អាចចូលរួមក្នុងសន្និសីទខាងលើ តាមរយៈការដាក់សំណើសុំចូលរួមមកនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ដោយភ្ជាប់មកជាមួយនូវគោលបំណងនិងប្រវត្តិរូបសង្ខេប យ៉ាងយូរត្រឹម ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧។

សូមទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
០២៣ ៩៩០ ១៩៦
nbccommunication@nbc.org.kh